ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...............១៩៧...........ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## សៀវភៅការងារ កម្មករនិយោជិតខ្មែរ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០៣៩៧/០០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នសរកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសរួមលេខ ១០០៩ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ មិនអាចប្រើកម្មករនិយោជិតខ្មែរដោយគ្មានសៀវភៅការងារឡើយ ហើយត្រូវបង្កលក្ខណៈងាយស្រួលឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីទៅធ្វើសៀវភៅការងារ នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

អ្នកនៅរាជធានីភ្នំពេញ និងនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ចំពោះអ្នកនៅរាជធានី-ខេត្ត ។

**ប្រការ ២.-**

នៅពេលស្នើសុំសៀវភៅការងារ កម្មករនិយោជិតម្នាក់ៗត្រូវយកទៅជាមួយនូវៈ

១-ពាក្យស្នើសុំសៀវភៅការងារបិទតែមប្រ៍ ១ ០០០ (មួយពាន់) រៀល ចំនួន០១ច្បាប់ ដោយមានភ្ជាប់ជាមួយនូវរូបថតចំពីមុខទំហំ ៣x៤ ស.ម ចំនួន ០៥សន្លឹក។

២-អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ចំនួន០១ច្បាប់។

៣-លិខិតបញ្ជាក់មុខរបរដែលចេញឱ្យដោយម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ចំនួន០១ច្បាប់។

៤-អាករសៀវភៅការងារដែលកំណត់ឱ្យបង់តែម្តងគត់ចំនួន ១០ ០០០ (ដប់ពាន់) រៀល។

**ប្រការ ៣.-**

ពេលជាមួយគ្នានឹងការចេញសៀវភៅការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តនីមួយៗ ក៏មានចេញជូនសាមីជន កម្មករនិយោជិតផងដែរនូវ "ប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ"។

**ប្រការ ៤.-**

នៅពេលដែលមានកម្មករនិយោជិតចូលធ្វើការងារ ឬឈប់ពីការងារសហគ្រាស គ្រឹះស្ថានណាមួយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិតនោះទៅចុះទិដ្ឋាការចូល ឬចេញ នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ ឬនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ចំពោះអ្នកនៅរាជធានី-ខេត្ត។

ការចុះទិដ្ឋាការនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ០៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីកម្មករនិយោជិតបានចូលធ្វើការ ឬឈប់ពីការងារ។

នៅពេលដែលមានការផ្លាស់ប្តូរមុខងារ និងប្រាក់ឈ្នួលរបស់កម្មករនិយោជិតម្តងៗ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ក៏ត្រូវយកសៀវភៅការងារទៅចុះទិដ្ឋាការឱ្យបានត្រឹមត្រូវ ដូចពេលចូលធ្វើការងារ ឬឈប់ពីការងារផងដែរ។

នៅពេលដែលកម្មករនិយោជិតឈប់ពីការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវប្រគល់សៀវភៅការងារជូនដល់សាមីជនកម្មករនិយោជិតវិញ។

**ប្រការ ៥.-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវបានអនុញ្ញាតឱ្យយកសៀវភៅការងារកម្មករនិយោជិតខ្មែរ ទៅប្រើប្រាស់ខុសពីគោលដៅឡើយ ហើយក៏មិនអាចចារមូលវិចារអ្វីនៅលើសៀវភៅការងារនោះផងដែរ។

**ប្រការ ៦.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក ១៦ នៃច្បាប់ស្ដីពីការងារ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>កន្លែងទទួល:</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៨
  "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ